ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពគណៈបញ្ជាការ ការពារសន្ដិសុខគោលដៅ ទីស្ដីការគណៈរដ្ឋមន្ត្រី និងទីស្ដីការនាយករដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្ដីសម្រេចលេខ ៧៤ សសរ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតគណៈបញ្ជាការ ការពារសន្ដិសុខគោលដៅទីស្ដីការគណៈរដ្ឋមន្ត្រី និងទីស្ដីការនាយករដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ ៖** ត្រូវបានកែសម្រួលសមាសភាពគណៈបញ្ជាការ ការពារសន្ដិសុខគោលដៅទីស្ដីការគណៈរដ្ឋមន្ត្រី និងទីស្ដីការនាយករដ្ឋមន្ត្រី ដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្ដម នាយឧត្ដមសេនីយ៍ | **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរង នៃ ខ.ភ.ម និងជា មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស | ជាប្រធាន |
| ២- | ឯកឧត្ដម នាយឧត្ដមសេនីយ៍ | **ឃួ ស៊ុនឡុង** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | ជាអនុប្រធាន |



www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៣- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហ៊ុយ ពិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ប្រចាំការដឹកនាំបញ្ជាបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន |
| ៤- | ឯកឧត្តម | **ឃឹម នុស្សីដា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួលពិធីនិង កិច្ចប្រជុំនានានៅវិមានសន្តិភាព ជាអនុប្រធាន |
| ៥- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ជួន សុវណ្ណ** | អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ និងជាស្នងការស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ជាអនុប្រធាន |
| ៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **តាន់ បញ្ញាវុធ** | នាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាអនុប្រធាន |
| ៧- | ឯកឧត្តម | **មួន លឹមហេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកទទួលបន្ទុកការងារជានាផ្គត់ផ្គង់ និងហិរញ្ញវត្ថុ |
| ៨- | ឯកឧត្តម | **សេង ទៀង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជានាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាសមាជិកទទួលការងារសម្របសម្រួលទូទៅនិងផ្គត់ផ្គង់ |
| ៩- | ឯកឧត្តម | **ឃួង ស្រេង** | អភិបាលរងរាជធានីភ្នំពេញ ជាសមាជិក ទទួលបន្ទុកការងារក្តាប់ព័ត៌មានទូទៅ ទប់ស្កាត់ ដោះស្រាយរាល់បាតុភាព និងរាល់ពាក្យបណ្តឹងផ្សេងៗ |
| ១០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហ៊ុន ម៉ាណែត** | មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ព ជើងគោក នាយរងសេនាធិការចំរុះ និងជា មេបញ្ជាការបញ្ជាការដ្ឋានជាតិកំលាំងពិសេសប្រឆាំងភេរវកម្ម ជាសមាជិក ទទួលផែនសន្តិសុខការពារកៀកសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងអន្តរាគមន៍ពិសេស |
| ១១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចៅ តុល** | នាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នាយរងសេនាធិការចំរុះ និងជាមេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ១២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឡៀង សារុន** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកអចិន្ត្រៃយ៍ |
| ១៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចន្ទ ពិសេន** | មេបញ្ជាការរង បញ្ជាការដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិកទទួលការងារអន្តរាគមន៍ |
| ១៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ព្រហ្ម ឌិន** | មេបញ្ជាការយោធភូមិភាគពិសេស ជាសមាជិកទទួលការងារអន្តរាគមន៍ |
| ១៥- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **អ៊ុង សារិទ្ធ** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកទទួលផែនអន្តរាគមន៍ |



www.pheakdeylaw.com

| | | | |
|---|---|---|---|
| ១៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **គោគ ចន្ថា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកអចិន្ត្រៃយ៍ទទួលបន្ទុកដឹកនាំបញ្ជាកម្លាំងការពារសន្តិសុខក្នុងបរិវេណទីស្ដីការគណៈរដ្ឋមន្ត្រី និង ទីស្ដីការនាយករដ្ឋមន្ត្រី |
| ១៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ ចារុវណ្ណ** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកទទួលផែនសន្តិសុខផ្ទាល់ |
| ១៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ សុវណ្ណា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ១៩- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **រ័ត្ន ស្រ៊ាង** | មេបញ្ជាការ កងរាជអាវុធហត្ថរាជធានីភ្នំពេញ ជាសមាជិក |
| ២០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សួន ពិរុណា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឡេង ម៉ុនណា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ុន រ៉ា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ៃ សារឿន** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក |
| ២៤- | ឧត្តមសេនីយ៍ទោ | **នឹម ស៊ីណារក្ស** | មេបញ្ជាការ កងអន្តរាគមន៍លេខ៣១១ ជាសមាជិក |
| ២៥- | ឧត្តមសេនីយ៍ទោ | **ខ៊ាន់ សារឿន** | អនុប្រធាន នាយកដ្ឋាននគរបាលការពារ ជាសមាជិក |

**ប្រការ ២** ៖ គណៈបញ្ជាការនេះ មានភារកិច្ចដូចខាងក្រោម ៖

- ការពារសន្តិសុខ សុវត្ថិភាព ក្នុង និងជុំវិញអគារទីស្ដីការគណៈរដ្ឋមន្ត្រី និងអគារទីស្ដីការនាយករដ្ឋមន្ត្រី ២៤ម៉ោងលើ២៤ម៉ោង
- គ្រប់គ្រងកងកម្លាំងប្រដាប់អាវុធទាំងអស់ដែលមានភារកិច្ចទទួលខុសត្រូវការពារក្នុងអគារទីស្ដីការគណៈរដ្ឋមន្ត្រី និងអគារទីស្ដីការនាយករដ្ឋមន្ត្រី
- ពិនិត្យជាតិផ្ទុះ ជាតិពុល ព្រមទាំងឆែកឆេររាល់សម្ភារៈ មធ្យោបាយ និងសមាសភាពទាំងអស់ដែលចូលក្នុងបរិវេណអគារទីស្ដីការគណៈរដ្ឋមន្ត្រី និងអគារទីស្ដីការនាយករដ្ឋមន្ត្រី
- សហការជាមួយគណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួលពិធីនិងកិច្ចប្រជុំនានាក្នុងអគារសន្តិភាព
- សហការជាមួយសមត្ថកិច្ច អជ្ញាធរដែនដីពាក់ព័ន្ធ តាមដានក្តាប់សភាពការណ៍ ព្រមទាំងទប់ស្កាត់ រាល់សកម្មភាពភូដកម្ម បាតុកម្ម និងការតវ៉ាផ្សេងៗ ដែលនាំអោយប៉ះពាល់ដល់ការរៀបចំពិធីក្នុងអគារទីស្ដីការគណៈរដ្ឋមន្ត្រី និងអគារទីស្ដីការនាយករដ្ឋមន្ត្រី
- ពិនិត្យរាល់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចសន្តិសុខ នៅក្នុង និងជុំវិញអគារទីស្ដីការគណៈរដ្ឋមន្ត្រី និងអគារទីស្ដីការនាយករដ្ឋមន្ត្រី ។

**ប្រការ ៣** ៖ គណៈបញ្ជាការ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** ៖ អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានគណៈបញ្ជាការ ។



www.pheakdeylaw.com

**ប្រការ ៥ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសមាសភាពគណៈបញ្ជាការដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៧*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ៥*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com